# សុន្ទរកថា
# ឯកឧត្តម ប្រាក់ សុខុន ឧបនាយករដ្ឋមន្ត្រី
# រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
# ក្នុងពិធីបើកសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២២
# និងទិសដៅឆ្នាំ២០២៣
# របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
# ថ្ងៃទី១ ខែមីនា ឆ្នាំ២០២៣

--------------------------------

- ឯកឧត្តម លោកជំទាវ ជាភ្ញៀវកិត្តិយស
- ឯកឧត្តម លោកជំទាវ លោក លោកស្រី
- អង្គសន្និបាតទាំងមូលជាទីមេត្រី!

ខ្ញុំមានសេចក្តីសោមនស្សរីករាយ សូមស្វាគមន៍យ៉ាងកក់ក្តៅបំផុតចំពោះវត្តមានរបស់ ឯកឧត្តម លោកជំទាវ ជាភ្ញៀវកិត្តិយសដែលអញ្ជើញមកពីក្រសួង-ស្ថាប័នពាក់ព័ន្ធនានា ក៏ដូចជាវត្តមានរបស់ថ្នាក់ដឹកនាំ ប្រធានស្ថានបេសកកម្មយើងនៅបរទេស អ្នកការទូត មន្ត្រី បុគ្គលិក នៃក្រសួងការបរទេស និងសហ-ប្រតិបត្តិការអន្តរជាតិ ក្នុងពិធីបើកសន្និបាតប្រចាំឆ្នាំរបស់យើង នាព្រឹកនេះ។

ខ្ញុំសូមអរគុណ **ឯកឧត្តម អ៊ុច បូរិទ្ធ** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជារដ្ឋលេខាធិការប្រចាំការ ដែលបានរាយការណ៍គ្រប់ជ្រុងជ្រោយអំពីសភាពការណ៍តំបន់ និងអន្តរជាតិ ព្រមទាំងរំលេចនូវសមិទ្ធផលសំខាន់ៗ ដែលក្រសួងសម្រេចបានក្នុងការការការពារផលប្រយោជន៍ស្នូលរបស់ជាតិ ការអនុវត្តនយោបាយការបរទេសឯករាជ្យ ផ្អែកលើច្បាប់អន្តរជាតិ ប្រកបដោយភាពទន់ភ្លន់ បត់បែន តែម៉ឺងម៉ាត់ របាយការណ៍ក៏បានរំលេចផងដែរនូវការបន្តពង្រឹងឡើងវិញនូវចំណងទាក់ទងជាមួយមិត្តចាស់ និងបង្កើនមិត្តថ្មី ការជំរុញការងារ

ការទូតសេដ្ឋកិច្ច ទេសចរណ៍ និងវប្បធម៌ ការចូលរួមកាន់តែសកម្មក្នុងបុព្វហេតុ សន្តិភាព ស្ថិរភាព និងវិបុលភាព និងចូលរួមដោះស្រាយបញ្ហាប្រឈមនានាលើសកលលោក រួមទាំងបន្តជំរុញការដ្ឋានកំណែទម្រង់ស្ថាប័នក្នុងក្រសួង។

បន្តិចទៀតនេះ យើងនឹងបានស្តាប់បទឧទ្ទេសនាមរបស់ **ឯកឧត្តមបណ្ឌិត សឹង រេត** តំណាងឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ស្តីពី «ការត្រៀមខ្លួនចំពោះបញ្ហាប្រឈម និងដំណោះស្រាយក្រោយកម្ពុជាចាកចេញពីប្រទេសអភិវឌ្ឍន៍តិចតួច (LDC)» និងបទឧទ្ទេសនាមរបស់ **លោក សួន សុផល** តំណាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ស្តីពី «យុទ្ធសាស្ត្រជំរុញការវិនិយោគ៖ បញ្ហាប្រឈម និងដំណោះស្រាយ»។ ប្រធានបទទាំងពីរនេះ មានសារៈសំខាន់ណាស់ នៅក្នុងបរិបទមួយដែលកម្ពុជាកំពុងទទួលបានផ្លែផ្កាពីសុខសន្តិភាព ដែលបានអនុញ្ញាតឲ្យយើងបន្តអភិវឌ្ឍសង្គម-សេដ្ឋកិច្ចឥតឈប់ឈរ រហូតឈានឆ្ពោះទៅការចាកចេញពីឋានៈ «ប្រទេសអភិវឌ្ឍន៍តិចតួច» ជាផ្លូវការឆាប់ៗខាងមុខនេះ។ ខ្ញុំសុំយកឱកាសនេះ អរគុណដ៏ស្មោះ ឯកឧត្តមតំណាងទាំងពីរ ចំពោះវិភាគទានដ៏សំខាន់នេះ។

## ឯកឧត្តម លោកជំទាវ លោក លោកស្រី

នៅពេលរសៀលនេះ និងថ្ងៃស្អែកពេញមួយថ្ងៃ ខ្ញុំនឹងដឹកនាំកិច្ចប្រជុំចង្អៀតដែលមានការចូលរួមពីថ្នាក់ដឹកនាំក្រសួងការបរទេស ព្រមទាំងឯកអគ្គរាជទូតតំណាងអចិន្ត្រៃយ៍ និងអគ្គកុងស៊ុលរបស់យើង ប្រចាំនៅបរទេសសរុបទាំងអស់ ៤៣ រូប។ កិច្ចប្រជុំចង្អៀតនេះ ក៏នឹងមានការចូលរួមផងដែរពីសំណាក់**ឯកឧត្តម សុខ ចិន្តាសោភា** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាអគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។ កិច្ចពិភាក្សានឹងផ្តោតលើប្រធានបទសំខាន់បី ជាអាទិ៍ (១) ការប្រែប្រួលភូមិសាស្ត្រនយោបាយសកលលោក និងផលប៉ះពាល់មកលើ

តំបន់ និងកម្ពុជា (២) ការងារការទូតសេដ្ឋកិច្ច និង (៣) កំណែទម្រង់ស្ថាប័នផ្ទៃក្នុងក្រសួង ដែលនឹងផ្តោតទៅលើការពិនិត្យបញ្ហាប្រឈម និងការស្វែងរកដំណោះស្រាយ។ យើងនឹងធ្វើការបូកសរុបលទ្ធផលសំខាន់ៗ នៃកិច្ចពិភាក្សាទាំងនេះ គោរពរាយការណ៍ជូន **សម្តេចតេជោនាយករដ្ឋមន្ត្រី** នាពិធីបិទសន្និបាតនៅរសៀលថ្ងៃទី៣ ខែមីនា ដើម្បីទទួលនូវអនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់បំផុត និងចក្ខុវិស័យវែងឆ្ងាយ ប្រកបដោយគតិបណ្ឌិតរបស់ **សម្តេច** ឆ្ពោះទៅសម្រេចឱ្យបាននូវជោគជ័យថ្មីៗថែមទៀត ក្នុងការងារការទូតរបស់យើង។

## ឯកឧត្តម លោកជំទាវ លោក លោកស្រី

ក្នុងរយៈពេល ៥ឆ្នាំចុងក្រោយនេះ ពិភពលោកបន្តវិវត្តន៍ទៅរកប្រព័ន្ធអន្តរជាតិមួយដែលមានលក្ខណៈសកល ពហុប៉ូល និងស្មុគ្រស្មាញ។ ការវិវត្តន៍នេះបាននាំមកនូវការផ្លាស់ប្តូរនៃទំនាក់ទំនងអន្តរជាតិយ៉ាងជ្រាលជ្រៅ ឆាប់រហ័ស ពិបាកប៉ាន់ស្មាន និងប្រកបដោយគ្រោះថ្នាក់ ទាំងសម្រាប់តំបន់អាស៊ី-ប៉ាស៊ីហ្វិក ទាំងសម្រាប់ពិភពលោក។

ការប្រែប្រួលទាំងនេះ បានស្តែងចេញតាមរយៈនៃការប្រកួតប្រជែងកាន់តែតានតឹង និងស្មុគ្រស្មាញឡើង និងលើវណសិរ្សកាន់តែច្រើន រវាងមហាអំណាចធំបំផុតទាំង២ គឺ ស.រ.អ. និង ចិន។ ការប្រជែងនេះបានបង្កើតឡើងនូវស្ថានភាពដ៏លំបាកសម្រាប់ប្រទេសមធ្យម និងតូច ក្នុងការកែសម្រួលយុទ្ធសាស្ត្រ និងការប្រកាន់នូវជំហររបស់ខ្លួន ដើម្បីឆ្លើយតបនឹងការប្រែប្រួលទាំងនោះ និងការពារផលប្រយោជន៍ជាតិរៀងៗខ្លួន។ ជាមួយនេះ កត្តាខាងក្រៅជាច្រើនទៀត ក៏ជះឥទ្ធិពលមកលើដំណើរវិវត្តន៍នេះ តួយ៉ាង ផលប៉ះពាល់ធ្ងន់ធ្ងរ និងចំរុះដែលបណ្តាលមកពីជម្ងឺរាលដាលកូវីដ-១៩ ការប្រែប្រួលអាកាសធាតុ និងបញ្ហាសន្តិសុខមិនប្រពៃណីផ្សេងទៀត។ ភ្នក់នៃភាពតានតឹងដែលមានស្រាប់ ឬកំពុងធ្លាក់ក្នុងស្ថានភាពធ្ងន់ធ្ងរប្រកបដោយគ្រោះថ្នាក់ បន្តធ្វើឲ្យសហគមន៍

អន្តរជាតិខ្វល់ខ្វាយ និងចំណាយធនធាន ពេលវេលាសន្ធឹកសន្ធាប់ ឯវិបត្តិ និងសង្គ្រាមនៅតំបន់ខ្លះ នាំឲ្យរង្គោះរង្គើរដល់របៀបរបបសកលលោកផ្អែកលើច្បាប់អន្តរជាតិ ប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សន្តិភាព សន្តិសុខ ស្ថេរភាពនៃតំបន់ទាំងនោះ ឬក៏ឆ្ងាយជាងនេះ។

ចំណុច ឬ បាតុភូតលេចធ្លោជាងគេក្នុងដើមសតវត្សទី២១ នេះ គឺការងើបឡើងយ៉ាងជាក់ច្បាស់របស់ចិន មកជាមហាអំណាចសេដ្ឋកិច្ចដ៏មានឥទ្ធិពល មានទម្ងន់ខាងភូមិសាស្ត្រនយោបាយ ការទូត និងយោធាកាន់តែធំឡើង ដំណាលពេលអាមេរិកជាប់ផុងក្នុងសង្គ្រាមនៅអាហ្វហ្គានីស្ថាន អ៊ីរ៉ាក់ និងក្នុងប្រទេសមួយចំនួនទៀត ក្នុងនាមប្រឆាំងភេរវកម្ម ឬ ការពារលទ្ធិប្រជាធិបតេយ្យ។ ការងើបឡើងរបស់ប្រទេសចិនបានបង្កទៅជាការប្រឈមជាយុទ្ធសាស្ត្រដ៏ធំបំផុតសម្រាប់ ស.រ.អា ចំពោះការរក្សាឋានៈជាមហាអំណាចទីមួយនៃពិភពលោក។ ទំនាក់ទំនងកាន់តែលំបាកឡើងរវាងស.រ.អ. និង ចិន ជះឥទ្ធិពលសំខាន់បំផុតលើដំណើរនៃប្រព័ន្ធអភិបាលកិច្ច និងសណ្តាប់ធ្នាប់សកល។ ការប្រកួតប្រជែងនេះ បានស្តែងឡើងតាមរូបភាពចំរុះ និងតាមការដាក់ចេញនូវគំនិតផ្តួចផ្តើមជាច្រើន ដែលជាការតបតគ្នាមិនដាច់។

ឆ្លើយតបនឹងការងើបឡើងនៃអំណាច និងឥទ្ធិពលរបស់ចិន ចាប់តាំងពីប្រទេសនេះបានដាក់ចេញនូវគំនិតផ្តួចផ្តើមខ្សែក្រវ៉ាត់និងផ្លូវ (BRI) នៅឆ្នាំ ២០១៣ មក សហរដ្ឋអាមេរិកក៏បានដាក់ចេញនូវយុទ្ធសាស្ត្រ «ឥណ្ឌូ-ប៉ាស៊ីហ្វិកសេរី និងបើកចំហរ» (បន្ទាប់ពីនយោបាយងាកមករក អាស៊ី - Pivot to Asia - របស់លោក Obama), ដាស់ និងពង្រឹងឡើងវិញនូវសម្ព័ន្ធភាពរបស់ខ្លួននៅអឺរ៉ុប និងនៅអាស៊ី ព្រមទាំងកសាងឡើងនូវអង្គការភូមិសាស្ត្រនយោបាយ ដើម្បីហ៊ុំព័ទ្ធចិន តួយ៉ាង «កិច្ចសន្ទនាសន្តិសុខចតុភាគី» (QUAD), «កិច្ចព្រមព្រៀងសន្តិសុខត្រីភាគី» (AUKUS), និង «ក្របខណ្ឌសេដ្ឋកិច្ចឥណ្ឌូ-ប៉ាស៊ីហ្វិក» (IPEF) ជាដើម។ «យុទ្ធសាស្ត្រសន្តិសុខជាតិ» របស់ស.រ.អា. ដែលចេញផ្សាយ

នាខែតុលា ២០២២ ថ្មីៗនេះ បានបង្ហាញឲ្យឃើញកាន់តែច្បាស់នូវការប្តេជ្ញារបស់អាមេរិកក្នុងការប្រឆាំងចិន ដោយយកការប្រកួតប្រជែងផ្នែកយុទ្ធសាស្ត្រជាមួយចិនជា**អាទិភាពទី១**។

ចាប់តាំងពីបានក្លាយជាមហាអំណាចសេដ្ឋកិច្ចទី២ នៃពិភពលោកនៅឆ្នាំ២០១៣ ប្រទេសចិនកាន់តែមានទំនុកចិត្តលើសមត្ថភាព អំណាច និងឥទ្ធិពលរបស់ខ្លួន ក្នុងកិច្ចការតំបន់ និងពិភពលោក។ ចិនប្រកាសនូវការប្តេជ្ញាចិត្តយ៉ាងមុតមាំក្នុងការកសាងនូវ «មហាប្រទេសសង្គមនិយមទំនើបលើគ្រប់វិស័យ» តាមលក្ខណៈពិសេសរបស់ចិន ដែល «គ្មាននរណាអាចរារាំងបានឡើយ»។

អាស្រ័យដោយកំណើនសេដ្ឋកិច្ចខ្ពស់ និងស្ថេរ ក្នុងរយៈពេលច្រើនទស្សវត្សជាប់ៗគ្នា ប្រទេសចិនបានដើរតាមទាន់ស.រ.អ. សឹងគ្រប់វិស័យ។ ឥទ្ធិពលសេដ្ឋកិច្ចរបស់ចិននៅតំបន់ជាច្រើនលើពិភពលោកមានលក្ខណៈទូលាយ និងកើនឡើងជាលំដាប់។ ចិនជាដៃគូសំខាន់បំផុតផ្នែកសេដ្ឋកិច្ច និងពាណិជ្ជកម្ម សម្រាប់សឹងគ្រប់ប្រទេសនៅអាស៊ី។ ចិនមានលទ្ធភាពបង្កើត និងអនុវត្តនូវគំនិតផ្តួចផ្តើមខ្សែក្រវ៉ាត់ និងផ្លូវ (BRI) ហើយថ្មីៗនេះទៀត កៀរគរ «ក្រុមមិត្ត» នៃ «គំនិតផ្តួចផ្តើមអភិវឌ្ឍន៍សកល» (GDI) ក៏ដូចជាបង្កើតនូវ «គំនិតផ្តួចផ្តើមសន្តិសុខសកល» (GSI)។ ជាមួយនេះ ចិនក៏ចាប់ដៃរុស្ស៊ីកសាងនូវទំនាក់ទំនងយុទ្ធសាស្ត្រ និងយោធា ដើម្បីឆ្លើយតបទៅនឹងសម្ពាធ និងការប្រឈមដែលចេះតែកើនឡើងជាមួយក្រុមប្រទេសខាងលិច ដែលបង្កឲ្យមាននូវស្ថានភាពមួយស្រដៀងគ្នានឹងសម័យកាលសង្គ្រាមត្រជាក់។ ចិន និងរុស្ស៊ី ក៏ចាប់ដៃគ្នាក្នុងការជម្រុញឲ្យ «ងាកចេញពីប្រព័ន្ធទូទាត់អន្តរជាតិដែលត្រួតត្រាដោយលោកខាងលិច» ដើម្បីកាត់បន្ថយហានិភ័យនៃការដាក់ទណ្ឌកម្មនានា ព្រមទាំងបង្កើននូវកិច្ចសហប្រតិបត្តិការ និងការគាំទ្រគ្នាទៅវិញទៅមក ផ្នែកបច្ចេកវិទ្យា និងលំហរអ៊ិនធឺណែត។ ក្នុងបរិបទដែលសង្គ្រាម

នៅអ៊ុយក្រែនបន្តវិវត្តន៍កាន់តែស្មុគស្មាញ និងប្រកបដោយគ្រោះថ្នាក់នោះ តួនាទី និងការសម្រេចរបស់ចិន នឹងមានសារៈសំខាន់បំផុតសម្រាប់អនាគតនៃសង្គ្រាមនេះ និងអនាគតនៃសណ្តាប់ធ្នាប់ពិភពលោក។ **ប្រធានបទទី១** នៃការពិភាក្សារបស់យើង នឹងផ្តោតទៅលើផលប៉ះពាល់នៃការប្រែប្រួលភូមិសាស្ត្រនយោបាយទាំងនេះមកលើកម្ពុជា ការគិតគូរជាយុទ្ធសាស្ត្រ ការប្រកាន់គោល-ការណ៍ គោលជំហររបស់យើងក្នុងស្ថានភាពដ៏ស្មុគស្មាញ និងគ្រោះថ្នាក់នេះ ដើម្បីការពារឲ្យបាននូវប្រយោជន៍ស្នូលរបស់ជាតិ និងប្រជាជនយើង។

**ជម្ងឺរាលដាលកូវីដ-១៩** បានបង្កមហន្តរាយនៅគ្រប់ច្រកល្ហកនៃពិភព-លោក ក្នុងរយៈពេល ៣ឆ្នាំ កន្លងមកនេះ ហើយប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ប្រព័ន្ធសុខាភិបាលសាធារណៈ កាត់ផ្តាច់ ឬធ្វើឲ្យរអាក់រអួលដល់ច្រវ៉ាក់ផ្គត់ផ្គង់សកល ប៉ះពាល់ជ្រាលជ្រៅដល់សេដ្ឋកិច្ច និងសង្គម និងផ្តាច់យកជីវិតមនុស្សរាប់លាននាក់។ ក្នុងពេលដែលពិភពលោកកំពុងចាប់ផ្តើមស្តារសេដ្ឋកិច្ចឡើងវិញពីផលវិបាកនៃជម្ងឺនេះ ការកើតឡើង និងរីករាលដាលនៃវ៉ារីយ៉ង់ថ្មីៗ គួបផ្សំនឹងការប្រឈមដែលត្រូវដោះស្រាយក្នុងបរិបទសេដ្ឋកិច្ចសកលដ៏លំបាកនោះ ក៏បន្តគំរាមកំហែងសន្តិសុខខាងសុខភាព និងបន្ថយបង្អាក់ដំណើរការស្តារឡើងវិញនេះដែរ។ ក្នុងស្ថានភាពបែបនេះ ការពិភាក្សារបស់យើងនឹងត្រូវផ្តោតទៅលើដំណោះស្រាយនានា ដែលប្រសើរបំផុត ដើម្បីទាក់ទាញការវិនិយោគពីបរទេស ការបង្កើនទេសចរ ការនាំចេញផលិតផលរបស់យើង ពិសេសនៅពេលកម្ពុជាលែងទទួលបានភាពអនុគ្រោះក្នុងឋានៈជាប្រទេសអភិវឌ្ឍន៍តិចតួចនាពេលខាងមុខ។

**កំណែទម្រង់ផ្ទៃក្នុងក្រសួង** យើងបាននាំមកនូវផ្លែផ្កាជាច្រើន ក្នុងការលើកកំពស់ប្រសិទ្ធភាព វិជ្ជាជីវៈ និងភាពមុតស្រួចនៃអ្នកការទូតយើង។ យ៉ាងណាក៏ដោយ ក៏ការកែទម្រង់នេះ នឹងត្រូវបន្តទៅទៀត ដើម្បីប្រែក្លាយក្រសួងការបរទេស និងជួរអ្នកការទូតរបស់យើង ទៅជាសេនាធិការ និងជាយុទ្ធជន

ឈានមុខក្នុងការការពារប្រយោជន៍ប្រទេសជាតិ និងប្រជាជនយើង នៅលើឆាកអន្តរជាតិ។ **ប្រធានបទទី៣** នៃការពិភាក្សារបស់យើង នឹងពិនិត្យពិចារណាឲ្យកាន់តែស៊ីជម្រៅ ថាតើកំណែទម្រង់កន្លងមកបានទទួលផលយ៉ាងម៉េចខ្លះ? តើជួបបញ្ហាប្រឈមអ្វីខ្លះ ហើយត្រូវដោះស្រាយយ៉ាងណា?

ខាងលើនេះ គឺជាគំនិតខ្លះៗ ដែលថ្នាក់ដឹកនាំ មន្ត្រីការទូត និងមន្ត្រីយើងទាំងអស់ ត្រូវខិតខំប្រមូលផ្ដុំបញ្ញាញាណ ជជែកវែកញែក ផ្លាស់ប្ដូរទស្សនៈគ្នា លើកជាគំនិតផ្ដួចផ្ដើម ជាផែនការ និងវិធានការការងារ សំដៅសម្រេចឱ្យបាននូវបេសកកម្មដ៏ឧត្ដុង្គឧត្ដមជូនជាតិមាតុភូមិ ពិសេសនៅក្នុងកិច្ចការពារផលប្រយោជន៍ និងលើកស្ទួយកិត្យានុភាពជាតិយើង។

ខ្ញុំជឿជាក់ថា សន្និបាតរបស់យើងនឹងប្រព្រឹត្តទៅដោយភាពសកម្ម និងជូនពរឲ្យកិច្ចពិភាក្សារបស់យើងទទួលបានជោគជ័យផ្លែផ្កាត្រចះត្រចង់។ ជាទីបញ្ចប់ ខ្ញុំសូមជូនពរ ឯកឧត្តម លោកជំទាវ លោក លោកស្រី ភ្ញៀវកិត្តិយសទាំងអស់ សូមទទួលបានសិរីសួស្ដី ជ័យមង្គល វិបុលសុខគ្រប់ប្រការ។

ខ្ញុំសូមប្រកាសបើកជាផ្លូវការ «**សន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២២ និងទិសដៅការងារឆ្នាំ២០២៣ របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ**» ចាប់ពីពេលនេះតទៅ៕

**សូមអរគុណ**!